# កិច្ចការស្រាវជ្រាវ

បណ្ឌិត ព្រុំ ទេវី

# រំលឹកមេរៀន

- មេរៀនទី១
  - ចំណោទបញ្ហាសំខាន់
  - ចំណោទបញ្ហាបន្ទាប់បន្សំ
- មេរៀនទី២
  - គោលដៅនៃការសិក្សា
  - ទំនាក់ទំនងជាមួយចំណោទបញ្ហា

# កិច្ចការស្រាវជ្រាវ

- និយមន័យនៃការស្រាវជ្រាវ
- ប្រភេទផ្សេងៗនៃកិច្ចការគរុកោសល្យ និង
- ប្រភេទផ្សេងៗនៃគម្រោងស្រាវជ្រាវ

# និយមន័យនៃការស្រាវជ្រាវ

- Re + Search
- Re= again, anew, or over again ម្តងទៀត ជាថ្មី ឡើងវិញ ឬជាថ្មីម្តងទៀត
- Search = To examine closely and carefully, to test and try or to probe
- ពិនិត្យផិតដល់ និងដោយយកចិត្តទុកដាក់សាកល្បង។

# និយមន័យនៃការស្រាវជ្រាវ

- ការសិក្សាប្រកបដោយការយកចិត្តទុកដាក់ មានប្រព័ន្ធច្បាស់លាស់ អត់ធ្មត់ និងជាការសើុបអង្កេតក្នុងវិស័យនៃចំណេះដឹង ទាំងនេះធ្វើឡើងដើម្បីបង្កើតសេចក្តីពិតឬគោលការណ៍។

# និយមន័យនៃការស្រាវជ្រាវ

- ឧទាហរណ៍
- ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១ ម៉ោង៨.៣០នាទីយប់ ធ្វើដំណើរក្នុងទីក្រុងភ្នំពេញ - ត្រូវបានហាមឃាត់
- ថ្ងៃទី១០ ខែ ឆ្នាំ ម៉ោង ដដែល - ត្រូវបានហាមឃាត់
- ថ្ងៃទី១១ ខែ ឆ្នាំ ម៉ោង ដដែល - ត្រូវបានហាមឃាត់

# និយមន័យនៃការស្រាវជ្រាវ

- សរុប៖
- ការធ្វើដំណើរក្នុងទីក្រុងភ្នំពេញ - ត្រូវបានហាមឃាត់
- ជាគោលការណ៍

# ប្រភេទផ្សេងៗនៃកិច្ចការគរុកោសល្យ

- កិច្ចការស្រាវជ្រាវនៅផ្ទះ
- របាយការណ៍បញ្ចប់ការសិក្សា
- របាយការណ៍កម្មសិក្សា
- សារណា
- និក្ខេបបទ

# ប្រភេទផ្សេងៗនៃគម្រោងស្រាវជ្រាវ

- Action Research Design
- Case Study Design
- Causal Design
- Cross-Sectional Design
- Descriptive Design
- Experimental Design
- Exploratory Design
- Field Research Design
- Historical Design
- Longitudinal Design
- Mixed-Method Design
- Observational Design
- Systematic Review

# Action Research Design

- ផ្ទាល់ចូលរួមក្នុងព្រឹត្តិការណ៍ ច្រើនដង លុះត្រាតែយល់ពីព្រឹត្តិការណ៍នោះច្បាស់។
- ភាគច្រើនគេមិនអាចគ្រោងទុកជាមុនបាន ថាតើត្រូវធ្វើការសង្កេតអំពីអ្វី ដូច្នេះហើយបើឃើញសកម្មភាពមួយក្នុងព្រឹត្តិការណ៍កើតឡើងហើយ តែមិនទាន់យល់នឹងកត់ត្រាបានច្បាស់
- និស្សិតត្រូវអត់ធ្មត់បន្តការសង្កេតនិងសើុបសួរជាថ្មីម្តងទៀត។

# Action Research Design

- ផ្តល់នូវការយល់ដឹងយ៉ាងច្បាស់ពីសហគមន៍មួយ ព្រោះជាសកម្មភាពនៃការស្រាវជ្រាវបន់បែនទៅតាមលទ្ធផលដែលយើងចង់បាន ហើយមិនមែនជាការផ្ទៀងផ្ទាត់ទ្រឹស្តីណាមួយឡើយ។
- អាចដឹងគ្រប់ចំណុចដែលកើតមានឡើង។

# Action Research Design

- អត់មានព្រាងទុកមុន
- ការសិក្សាអំពីការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយ ការព្យាបាលជំងឺកូវីដ-១៩នៅមន្ទីរពេទ្យមួយ ជាឧទាហរណ៍នៃប្រធានបទ សម្រាប់ការជ្រើសរើសយក Action Research Design ។

# Case Study Design

- ជាការសិក្សាស៊ីជម្រៅទៅលើបញ្ហាអ្វីមួយ ខុសពីការអង្កេតឬការសិក្សាប្រៀបធៀប។
- ប្រើសម្រាប់បំពេញវិស័យដែលគេចង់សិក្សា បានន័យថា ដើមឡើយនិស្សិតអាចចាប់អារម្មណ៍លើវិស័យមួយយ៉ាងទូលាយ បន្ទាប់មកគេជម្រុះចោលនៅសល់តែ១ឬ២-៣ប៉ុណ្ណោះដែលងាយស្រួលធ្វើការស្រាវជ្រាវ។
- ផ្ទៀងផ្ទាត់ទ្រឹស្តីនិងគំរូ (model) ដែលអនុវត្តទៅនឹងព្រឹត្តិការណ៍ជាក់ស្តែង ហើយមានប្រយោជន៍ណាស់សម្រាប់បញ្ហាដែលគេមិនទាន់ស្គាល់សោះពីមុនមក។

# Case Study Design

- ស្គាល់ពីបញ្ហាអ្វីមួយដែលស្មុគស្មាញតាមរយៈការវិភាគបរិបទលក្ខខណ្ឌ នឹងទំនាក់ទំនងនៃព្រឹត្តិការណ៍ដែលបានកំណត់ចំនួនរួចជាស្រេច។ និស្សិតអាចប្រើបច្ចេកទេសផ្សេងៗដើម្បីប្រមូលទិន្នន័យនិងជឿជាក់លើប្រភពផ្សេងៗដើម្បីស៊ើបអង្កេត។
- ដឹងខ្លះៗពីមុនមក កាន់តែស៊ីជម្រៅ និងពេលខ្លះទៀតគេអាចដឹងរឿងរ៉ាវកម្រជាពិសេសទៀតផង។

# Case Study Design

- មិនអាចមានតម្លៃជាទូទៅទេ ដួនកាលគេមិនអាចរកឱ្យឃើញទំនាក់ទំនងហេតុនិងផលទៀតផង។

# Causal Design

- ជាការសិក្សាដែលផ្តោតលើទំនាក់ទំនងរវាងហេតុនិងផល។

# Causal Design

- បង្ហាញនូវទំនាក់ទំនងយ៉ាងពិតប្រាកដរវាងអថេរ ឯករាជ្យ និងមិនឯករាជ្យ និងមានលំដាប់លំដោយទៅតាមពេល។
- វិធីសាស្ត្រក៏អាចឱ្យនិស្សិតយល់ពីដំណើរការនៃទំនាក់ទំនងអថេរ អាចធ្វើឡើងវិញបាន និងងាយស្រួលប្រៀបធៀបលទ្ធផលនៃការសិក្សារបស់ក្រុមគោលដៅផ្សេងៗគ្នា។

# Causal Design

- មិនត្រឹមត្រូវទាំងអស់ដែរ ព្រោះទំនាក់ទំនងខ្លះមិនមែនជាហេតុ-ផល ឧទាហរណ៍ ការគេងច្រើនធ្វើឱ្យមនុស្សធ្វើការបានល្អ បើសិនជាទំនាក់ទំនងនេះពិតគ្រប់ករណីនោះ គេមិនចាំបាច់រៀនសូត្រអ្វីទេ។
- ក្នុងករណីនេះ អាចមានអថេរផ្សេងទៀតចូលរួម ដូចជា កម្រិតនិងជំនាញសិក្សា ឥរិយាបទរបស់មនុស្សជាដើម។ ដូច្នេះហើយក្នុង Causal Design មានពេលខ្លះលំបាកនឹងកំណត់ថាអថេរមួយណាជាហេតុដែលត្រូវកើតមុន និងអថេរណាជាផលដែលត្រូវកើតក្រោយ។

# Cross-Sectional Design

- ជាការសិក្សាផ្តោតទៅលើលក្ខណៈផ្សេងៗគ្នានៃអ្វីមួយ
- ដោយមិនគិតពីទំហំនៃពេល ជឿជាក់ទៅលើភាពខុសគ្នាដែលមានស្រាប់
- ក្រុមគោលដៅយកមកសិក្សា ផ្អែកលើភាពខុសគ្នាដែលមានស្រាប់នោះ។
- អាចវាស់វែងនូវចំណុចខុសគ្នារវាងមនុស្ស កម្មវត្ថុ ឬព្រឹត្តិការណ៍
- តែមិនមែនជាការផ្លាស់ប្តូរទេ។

# Cross-Sectional Design

- អាចផ្ដល់នូវទិដ្ឋភាពនិងការពាក់ព័ន្ធទាំងឡាយក្នុងចំណុចណាមួយនៃពេលបានយ៉ាងច្បាស់លាស់
- ខុសពីការធ្វើពិសោធន៍ ដែលគេព្យាយាមធ្វើឱ្យមានភាពខុសគ្នា ហើយរង់ចាំលទ្ធផល។
- ត្រូវការចំនួនគំរូធំ និងមិនពាក់ព័ន្ធនឹងទីតាំងភូមិសាស្ត្រទេ។
- ការអង្កេតជាបច្ចេកទេសប្រមូលទិន្នន័យ។

# Cross-Sectional Design

- ជាក់លាក់សម្រាប់តែចំណុចណាមួយនៃពេល
- មិនបង្ហាញការផ្លាស់ប្តូរទៅតាមពេលឡើយ
- មិនបង្ហាញទំនាក់ទំនងហេតុ-ផលដែរ។

# Descriptive Design

- សំណួរ
  - អ្នកណា (who)
  - ធ្វើអ្វី (what)
  - ពេលណា (when)
  - កន្លែងណា (where) និង
  - ដូចម្តេច(how) ពាក់ព័ន្ធនឹងចំណោទបញ្ហាស្រាវជ្រាវអ្វីមួយ។
- ការសិក្សាប្រភេទនេះ មិនផ្តោតទៅលើមូលហេតុ (why)ទេ
- ពិពណ៌នាតែអំពីអ្វីដែលមានស្រាប់។

# Descriptive Design

- ការសង្កេតបែបធម្មជាតិក្នុងបរិស្ថានមួយដែលមិនប្រែប្រួល
- ការស្រាវជ្រាវប្រភេទនេះ គេត្រូវការទិន្នន័យច្រើនសម្រាប់ធ្វើការវិភាគលម្អិត។

# Descriptive Design

- មិនអាចប្រើប្រាស់សម្រាប់ការស្វែងរកចម្លើយដាក់ច្បាស់ ឬបង្ហាញឱ្យឃើញថាសម្មតិកម្មណាមួយខុសទេ។
- លទ្ធផលបានមកពីការសង្កេត ដូច្នេះហើយមិនអាចទ្បើងវិញបានទេ
- ពឹងផ្អែកយ៉ាងខ្លាំងលើបញ្ជីសំណួរ និងបញ្ជីផ្ទៀងផ្ទាត់សម្រាប់សង្កេត។

# Experimental Design

- ផ្លាស់ប្តូរ ហេតុ (អថេរឯករាជ្យ) ហើយរង់ចាំពិនិត្យមើលផល (អថេរមិនឯករាជ្យ)។
  - មានក្រុមពិសោធន៍មួយ(Experimental Group)និង
  - ក្រុមត្រួតពិនិត្យមួយ (Control Group)។
- អថេរឯករាជ្យត្រូវដាក់ទៅក្នុងក្រុមពិសោធន៍ និងមិនមែនក្រុមត្រួតពិនិត្យទេ ហេតុដូច្នេះហើយ Experimental Design ត្រូវការច្រើនក្រុមនិងរង្វាស់ច្រើនក្នុងរយៈពេលវែង។

# Experimental Design

- អនុញ្ញាតឱ្យគ្រូតពិនិត្យស្ថានការណ៍របស់ក្រុមពិសោធន៍ ដឹងថាផលដែលកើតឡើងដោយសារហេតុអ្វី។

# Experimental Design

- បើសិនជាមូលហេតុគ្រាន់តែជាការនិមិត្ត លទ្ធផលដែលទទួលបានអាចមានតម្លៃមិនទូទៅសម្រាប់ស្ថានភាពជាក់ទេ។
- លក្ខខណ្ឌនិមិត្តមួយចំនួនអាចធ្វើឱ្យផ្លាស់ប្តូរឥរិយាបទឬចម្លើយរបស់អ្នកចូលរួម
- ចំណាយច្រើននិងមិនសមស្របសម្រាប់ការសិក្សាគុណបែបគុណភាពមួយចំនួន។

# Exploratory Design

- សម្រាប់ការសិក្សាណាដែលចំណោទបញ្ហាប្រហាក់ប្រហែលនេះមិនធ្លាប់មាន ឬមានការសិក្សាតិចតួចបំផុត។
- ដើម្បីកំណត់បច្ចេកទេសនៃការប្រមូលទិន្នន័យនិងការពាក់ព័ន្ធមួយចំនួនទៀតសម្រាប់ការស្រាវជ្រាវបន្តទៀត។

# Exploratory Design

- ឆ្លើយតបនឹងសំណួរថា
  - អ្វីទៅ (what)
  - ហេតុអ្វី (why)
  - យ៉ាងដូចម្តេច (how)
- ផ្តល់ឱកាសសម្រាប់កំណត់បញ្ហាថ្មីនិងផ្ទៀងផ្ទាត់គោលការណ៍ដែលមានស្រាប់។
- ជួយដល់អ្នកដឹកនាំ ដើម្បីសម្រេចចិត្តក្នុងកំណត់អាទិភាពនិងធនធានក្នុងការស្រាវជ្រាវ។

# Exploratory Design

- លទ្ធផលនៃការស្រាវជ្រាវមិនអាចមានតម្លៃជាទូទៅសម្រាប់ សកលស្ថិតិទាំងអស់ទេ។

# Field Research Design

- សង្កេតឬសម្ភាសន៍ក្រុមគោលដៅដោយប្រើបច្ចេកទេសប្រមូលទិន្នន័យតាមបែបគុណភាព ( ស្តាប់និងសង្កេត )
- សេចក្តីសន្និដ្ឋានកើតចេញមកពីការបកស្រាយនូវអ្វីដែលបានឃើញ គោលការណ៍ និងគំនិត។

# Field Research Design

- បំពេញនូវការយល់ដឹងពីចំណោទបញ្ហាដែលពាក់ព័ន្ធនឹងទីតាំងនិង/ឬក្រុមគោលដៅជាក់លាក់ណាមួយ ដែលទិន្នន័យមានស្រាប់មិនបានបញ្ជាក់
- ផ្ទៀងផ្ទាត់ និងបញ្ជាក់សារជាថ្មីនូវអ្វីដែលធ្លាប់បានដឹងតាមរយៈទ្រឹស្តីនិងលទ្ធផលនៃការស្រាវជ្រាវពីមុនៗមក។

# Field Research Design

- ចំណាយពេលនិងធនធានច្រើន ត្រូវអត់ធ្មត់និងព្យាយាមច្រើន
- ឥរិយាបទក្នុងពេលប្រមូលទិន្នន័យអាចឱ្យលទ្ធផលនៃការសិក្សាលម្អៀងខ្លះៗដែរ។

# Historical Design

- ដើម្បីប្រមូលផ្ទៀងផ្ទាត់ និងបូកសរុបព្រឹត្តិការណ៍ដែលកើតមានពីអតីតកាល ដើម្បីបង្កើត សេចក្តីពិត (fact) សម្រាប់គាំទ្រ ឬច្រានចោលសម្មតិកម្មណាមួយ។
- ប្រើប្រាស់ទិន្នន័យដែលមានស្រាប់និងភស្តុតាងឯកសារសំខាន់ៗដូចជា កំណត់ ហេតុប្រចាំថ្ងៃ កំណត់ត្រាផ្លូវការ របាយការណ៍ បណ្ណសារ ព័ត៌មានមិនមែនជាអត្ថបទ (ផែនទី រូបភាព សំឡេង និងវីដេអូ)
- ភាពជាក់ច្បាស់នៃការសិក្សាបែបនេះ ពឹងផ្អែកលើភាពជាក់ច្បាស់នៃទិន្នន័យដែរ។

# Historical Design

- ឥរិយាបទរបស់និស្សិតកំលុងពេលនៃការប្រមូលទិន្នន័យ មិនប៉ះពាល់ដល់លទ្ធផលនៃការសិក្សាទេ
- អាចវិភាគពីការប្រែប្រួលនិងដឹងយ៉ាងស៊ីជម្រៅពីបរិបថនៃចំណោទបញ្ហា
- ទិន្នន័យដែលនិស្សិតប្រមូលបានរួចហើយអាចប្រើប្រាស់សម្រាប់ការស្រាវជ្រាវអំពីចំណោទបញ្ហាផ្សេងទៀត។

# Historical Design

- សេចក្ដីសន្និដ្ឋានអាស្រ័យនឹងចំនួននិងគុណភាពឯកសារដែលប្រមូលបាន ហើយក៏មិនអាចសម្របសម្រួលទៅនឹងបរិបថបច្ចុប្បន្នដែរ។
- និស្សិតត្រូវចំណាយពេលច្រើនសម្រាប់បកស្រាយទិន្នន័យដែលមានស្រាប់
- ប្រភពទាំងនោះអាចខ្លះមិនមានជាប្រភេទអនឡាញ (Online) ទេ។
- ខ្លឹមសារនៃឯកសារដែលមានស្រាប់ អាចលម្អៀងទៅតាមការបកស្រាយរបស់អ្នកនិពន្ធដើម
- ហើយពេលខ្លះទៀតបរិមាណនៃឯកសារដែលមាន អាចមិនគ្រប់គ្រាន់សម្រាប់ឆ្លើយតបនឹងចំណោទបញ្ហា។

# Longitudinal Design

- សួរនិងសង្កេតអំពីចំនួនគំរូដដែលៗ
- មានគម្លាតពេលស្មើៗគ្នា ឬយ៉ាងហោចណាស់ប្រហាក់ប្រហែល ដើម្បីកំណត់ការផ្លាស់ប្តូរ។

# Longitudinal Design

- ដឹងពីមូលហេតុទាំងឡាយ និងការផ្លាស់ប្ដូរក្នុងអថេរតាមពេលកន្លងទៅ
- អាចប្រើប្រាស់លទ្ធផលនៃការស្រាវជ្រាវប្រភេទនេះដើម្បីធ្វើការព្យាករណ៍លទ្ធផលអ្វីមួយដែលគេរង់ចាំ។

# Longitudinal Design

- ការរក្សាឱ្យបានចំនួនគំរូឱ្យនៅដដែលក្នុងរយៈពេលវែងជាការលំបាក
- បច្ចេកទេសនៃការប្រមូលទិន្នន័យក៏អាចប្រែប្រួល
- ជួនកាលត្រូវការទិន្នន័យបែបគុណភាពដើម្បីពន្យល់ភាពប្រែប្រួលរបស់លទ្ធផលដែរ។

# Mixed-Method Design

- ប្រើបច្ចេកទេសនៃការប្រមូលទិន្នន័យតាមបែបគុណភាពផងនិងបែបបរិមាណផង
- អាចប្រើបច្ចេកទេសប្រមូលទិន្នន័យផ្សេងទៀតរួមផ្សំជាមួយផងក៏បានដែរ។

# Mixed-Method Design

- បំពេញភាពខ្វះចន្លោះឱ្យគ្នាទៅវិញទៅមក

# Mixed-Method Design

- ត្រូវមានសមត្ថភាពគ្រប់គ្រាន់ក្នុងការជ្រើសរើសយកបច្ចេកទេសប្រមូលទិន្នន័យ
- ជាការស្មុគស្មាញនិងអាចប្រើពេលច្រើន

# Observational Design

- កំណត់លទ្ធផលនៃការសិក្សាដោយធ្វើការប្រៀបធៀបអ្វីដែលគេបានឃើញ ទៅនឹងក្រុមត្រួតពិនិត្យ (CONTROL GROUP)
- មាន២បែប
  - ដោយផ្ទាល់ដែលក្រុមគោលដៅដឹងថាគេត្រូវបានសង្កេត និង
  - ដោយប្រយោលដែលក្រុមគោលដៅមិនដឹងថាត្រូវបានសង្កេត។

# Observational Design

- មិនតម្រូវឱ្យមានជាចាំបាច់នូវការរៀបចំទុកជាមុនទេនូវអ្វីដែលគេត្រូវសង្កេតនោះទេ
- អាចដឹងព័ត៌មានយ៉ាងស៊ីជម្រៅពីក្រុមគោលដៅ តាមរយៈការសង្កេតមើលសកម្មភាពទៅរបស់ក្រុមគោលដៅនៅក្នុងបរិស្ថានរបស់គេផ្ទាល់ និងទាញសេចក្ដីសន្និដ្ឋានបានយ៉ាងពិតប្រាកដ
- អាចរកឃើញអថេរដែលអាចមានសារៈសំខាន់សម្រាប់ប្រើក្នុងបច្ចេកទេសប្រមូលទិន្នន័យផ្សេងទៀត។

# Observational Design

- ចំណាយពេលច្រើនបន្តិចដើម្បីប្រមូលទិន្នន័យ
- មិនអាចធ្វើឡើងវិញបានទេ។
- លទ្ធផលដែលទទួលបានមានតម្លៃតែចំពោះសកលស្ថិតិដែលបានសង្កេតតែប៉ុណ្ណោះ
- អាចប្រែប្រួលពីអ្នកស្រាវជ្រាវម្នាក់ទៅអ្នកស្រាវជ្រាវម្នាក់ទៀត
- ពិបាកកំណត់ទំនាក់ទំនងហេតុនិងផល

# Systematic Review

- ឯកសារដែលមានស្រាប់ដែលគេចង់ស្រាវជ្រាវ យកមកពិនិត្យឡើងវិញ
- កំណត់អ្វីដែលមានហើយនិងអ្វីដែលមិនទាន់មាន
- ប្រើប្រាស់លទ្ធផលនៃការសិក្សាដែលគេធ្វើពីមុនរួចមកហើយនិងធ្វើការវិភាគលទ្ធផលទាំងនោះតែម្តង មិនចាំបាច់បន្ថែមចំណុចអ្វីថ្មីទេ។
- បើសិនជាអាច និស្សិតគួរពិភាក្សាជាមួយបណ្ណារក្ស ដើម្បីប្រមូលឯកសារឱ្យបានអស់។

# Systematic Review

- ជាការផ្សារភ្ជាប់លទ្ធផលនៃការសិក្សាដែលមានរួចមកអាចចៀសវាងភាពលម្អៀង ឬកំហុសបានច្រើន។
- ប្រើវិធីសាស្ត្រនេះក្នុងការបង្កើតសម្មតិកម្មក្នុងការសិក្សា ចៀសវាងការយល់ច្រឡំ ឬសិក្សាទៅលើអ្វីដែលមានគេធ្វើរួចមកហើយ។
- អាចប្រើសម្រាប់ការស្រាវជ្រាវជាបន្តទៀត រៀបចំគោលនយោបាយ ។ល។ព្រោះលទ្ធផលនៃការសិក្សាជាក់លាក់ខ្លាំងផ្អែកលើការសិក្សាមុនៗដែលគេបានធ្វើរួចមកហើយ។

# Systematic Review

- មិនបាន ផ្តល់គំនិតអ្វីថ្មីដល់និស្សិតទេ តែអាចដឹងពីចំណុចខ្វះខាតនៅក្នុងឯកសារដែលមានស្រាប់ប៉ុណ្ណោះ។
- ការប្រើប្រាស់ឯកសារដែលមិនទាន់បោះពុម្ពផ្សាយ អាចធ្វើឱ្យមានលម្អៀងខ្លះដែរ